សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ៥១ "ខ"

ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ២០២២

-សំណុំរឿងរដ្ឋប្បវេណីលេខ១៧១៣

-ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង៨នាទីព្រឹក នៅសាលាដំបូងរាជធានីភ្នំពេញ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៧១៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ [redacted] បូណា ភេទស្រី កើតថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៨០ ជនជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] ហួត (ស) ម្តាយឈ្មោះ [redacted] ជាហ្គិច (រ)ប្តីឈ្មោះ [redacted] សុវិចិត្រ មានកូន០១នាក់ ។

អ្នកតំណាងដោយអាណត្តិ "ដើមចោទ" ៖ លោកមេធាវី [redacted] អត្តលេខ១០៧២ និងលោក [redacted] អត្តលេខ២៣០៣ Tមានការិយាល័យតាំងនៅ [redacted] ។

និងចុងចម្លើយឈ្មោះ [redacted] សុវិចិត្រ ភេទប្រុស កើតថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧០ ជនជាតិខ្មែរ មុខរបរមន្ត្រីរាជការ មានទីលំនៅសព្វ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជាត(ស) ម្តាយឈ្មោះ [redacted] ទាង(ស)ប្រពន្ធឈ្មោះ [redacted] បូណាមានកូន០១នាក់ ។

អ្នកតំណាងដោយអាណត្តិ"ចុងចម្លើយ" ៖លោកស្រីមេធាវី [redacted] អត្តលេខ១០៨៤ មានការិយាល័យតាំងនៅអគារ [redacted] ។

## I. អង្គហេតុ និងចំណុចវិវាទ

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១-ប្តឹងសុំលែងលះប្តីឈ្មោះ [redacted] សុវិចិត្រ ។

២-សុំអំណាចមេបាលើកូន០១ នាក់ឈ្មោះ [redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៤។

៣-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ។

ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី

-ក្នុងរឿងនេះដើមចោទសុំឱ្យតុលាការចេញសាលក្រមដូចចំណុច(ក)ខាងលើ ដោយហេតុថា៖ រស់នៅមិនចុះសំរុងគ្នា ជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ។ ខ្លួននិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ០១០ ត្រឹមត្រូវតាមច្បាប់ ។

Scanned with CamScanner

គូភាគីបង្កើតបានកូន០១នាក់ឈ្មោះ[redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៤។ សព្វថ្ងៃរស់នៅជាមួយដើមចោទ ។ ទ្រព្យសម្បត្តិដែលដាក់ឈ្មោះ[redacted]បូណា និងឈ្មោះ [redacted]សុវិចិត្រ ជាម្ចាស់កម្មសិទ្ធិមានដូចខាងក្រោម៖

-ដីផ្ទះលេខ១៤មានទំហំ៤០៨ម$^2$ (ទំហំជាក់ស្តែង៣៣៥ម$^2$)ស្ថិតនៅផ្លូវលេខ៣៦៩ មានក្បាលដី១២ម៉ែត្រ និងបណ្តោយដល់ទន្លេ ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨មានស្នាមមេដៃរបស់លោកចៅសង្កាត់ព្រែកថ្មី សុំចែកជាពីរចំណែក ។

ទ្រព្យសម្បត្តិដែលដាក់ឈ្មោះដើមចោទ[redacted]បូណា ជាម្ចាស់កម្មសិទ្ធិ:

-ដីចំការស្វាយទំហំ១០៩០២ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ មានលិខិតធ្វើអំណោយផ្តាច់លេខ៧១១/០២០ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០របស់ឈ្មោះ[redacted] បូរ៉ា (អ្នកធ្វើអំណោយ) មានស្នាមមេដៃឈ្មោះ[redacted] រ៉ា ប្រធានភូមិចំពុះក្អែក១ និងហត្ថលេខាចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០របស់លោក[redacted] ចៅសង្កាត់ព្រែកថ្មី ។

-ដីទំហំ២៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ មានលិខិតធ្វើអំណោយផ្តាច់លេខ៧១២/០២០ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០របស់ឈ្មោះ[redacted] បូរ៉ា (អ្នកធ្វើអំណោយ)មានស្នាមមេដៃឈ្មោះ[redacted]ប៉ាក់ប្រធានភូមិកោះក្របី និងហត្ថលេខារបស់លោក[redacted] ចៅសង្កាត់ព្រែកថ្មី ។

-ដីផ្ទះទំហំ ១៦៣២ម៉ែត្រការ៉េ(បច្ចុប្បន្ន១៥៧២ម៉ែត្រការ៉េ) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានលិខិតធ្វើអំណោយផ្តាច់លេខ៦៦១/០២០ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩របស់ឈ្មោះ[redacted]ហ្គេច (អ្នកធ្វើអំណោយ) មានស្នាមមេដៃឈ្មោះ[redacted] ប៉ាក់ប្រធានភូមិកោះក្របី និងហត្ថលេខាចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់លោក[redacted]ចៅសង្កាត់ព្រែកថ្មី ។

**គ.អង្គហេតុដែលអះអាងដោយដើមចោទ**

-ដើមចោទឈ្មោះ[redacted] បូណា មានលោកមេធាវី [redacted] តំណាងដោយអាណត្តិបានថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្លួនប្តឹងសុំលែងលះពីប្តីឈ្មោះ[redacted] សុវិចិត្រ ដោយហេតុថា រស់នៅមិនចុះសំរុងគ្នា ជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ខ្លួននឹងឈ្មោះ[redacted] សុវិចិត្រ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ០១០ សៀវភៅអាពាហ៍ពិពាហ៍លេខ០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ ត្រឹមត្រូវតាមច្បាប់។ ក្រោយពីរៀបការរួចមានកូន០១នាក់ ឈ្មោះ[redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៤ កូនម្នាក់នាក់នេះខ្លួនសុំអំណាចមេបាដោយសព្វថ្ងៃកូនរស់នៅជាមួយខ្លួន សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនសុំឱ្យប្តីផ្តល់តាមលទ្ធភាព ។ ទ្រព្យសម្បត្តិរួមមាន៖

-ដីផ្ទះលេខ១៤មានទំហំ៤០៨ម$^2$ (ទំហំជាក់ស្តែង៣៣៥ម$^2$)ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និង ដីឡូត៍លេខ២៣២ មានទំហំបណ្តោយ១៧ម៉ែត្រទទឹង៨ម៉ែត្រ(១៣៦ម$^2$ ) ស្ថិតនៅភូមិព្រះពន្លា សង្កាត់ ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញមានកិច្ចសន្យាលក់ដីចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២



Scanned with CamScanner

សុំបែងចែកជាពីរចំណែកស្មើគ្នា ខ្លួនពុំមានបំណុលទេ ។ សព្វថ្ងៃខ្លួននិងចុងចម្លើយរស់នៅបែកគ្នានិងរកស៊ីទុកលុយផ្សេងគ្នាតាំងពីឆ្នាំ២០១៥ រហូតដល់សព្វថ្ងៃ ។

**ឃ.អង្គហេតុដែលអះអាងដោយចុងចម្លើយ**

-ចុងចម្លើយឈ្មោះ [redacted] សុវិចិត្រ មានមេធាវី [redacted] តំណាងដោយអាណត្តិបានថ្លែងការណ៍តបថា: ខ្លួនក៏ឯកភាពលែងលះពីប្រពន្ធឈ្មោះ [redacted] បូណា វិញដែរ ដោយហេតុថា រស់នៅមិនចុះសម្រុងគ្នា ជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត។ រៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ០១០ សៀវភៅអាពាហ៍ពិពាហ៍លេខ០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់ឃុំព្រែកថ្មី ។ ក្រោយពីរៀបការរួចមានកូន០១នាក់ ឈ្មោះ [redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ខែកក្កដាឆ្នាំ ២០០៤ ខ្លួនឯកភាពប្រគល់អំណាចមេបាទៅឱ្យដើមចោទ សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនខ្លួនផ្ដល់តាមលទ្ធភាព ។ ចំពោះទ្រព្យសម្បត្តិរួមមាន ៖

-ដីចំការស្វាយទំហំ១០៨០២ម៉ែត្រក្រឡា មានបង្កាន់ដៃក្បាលដីលេខ១២១០០៧០៤០៧៦១ ស្ថិតនៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ជាដីរបស់ឪពុកក្មេកឈ្មោះ [redacted] ហួត បានប្រគល់ជាអំណោយឱ្យប្ដីប្រពន្ធកូនក្ដីខ្លួន ។តែការផ្ដល់ជាអំណោយនៅពេលនោះពុំបានធ្វើលិខិតស្នាមអ្វីទេ គ្រាន់តែប្រាប់សាច់ញាតិខាងកូនក្ដីខ្លួន,ប្រពន្ធកូន,បងប្អូនបង្កើត,មេភូមិ,មេឃុំនិងអ្នកជិតខាងឱ្យដឹងឮ ថាដីខាងលើនេះគឺឪពុកក្មេកប្រគល់ជាអំណោយចំណងដៃមកឱ្យឈ្មោះ [redacted] សុវិចិត្រ និងប្រពន្ធឈ្មោះ [redacted] បូណា ។ ក្រោយពីបានទទួលអំណោយដីខាងលើកូនក្ដីខ្លួនបានរៀបចំធ្វើរបងព័ទ្ធជុំវិញដី ធ្វើរោងចាំចំការ ដាំដើមស្វាយបន្ថែម រៀបចំទុយោដាក់ទឹកគ្រប់ដើមស្វាយ ចាក់ដី និងកាយដីធ្វើស្រះចាប់តាំងពីឆ្នាំ២០០៤រហូតដល់បច្ចុប្បន្នកូនក្ដីខ្លួន ចំណាយកម្លាំងកាយកម្លាំងចិត្ត ចំណាយប្រាក់ជាច្រើនដើម្បីអភិវឌ្ឍន៍ដីចំការស្វាយនេះ ។ លុះនៅឆ្នាំ២០២០ទើបកូនក្ដីខ្លួនដឹងថាឈ្មោះ [redacted] បូរ៉ា ត្រូវជាបងបង្កើតប្រពន្ធកូនក្ដីខ្លួនបានកែបន្លំប្រវត្តិដី លួចធ្វើលិខិតទិញលក់ដីក្លែងក្លាយចំនួន០២កន្លែងមាន៖ក្លែងបន្លំធ្វើលិខិតលក់ដីក្លែងក្លាយចុះថ្ងៃទី១០ខែកក្កដាឆ្នាំ១៩៨៦ ឱ្យឈ្មោះ [redacted] ជៀប ឈរឈ្មោះជាអ្នកលក់ដី ឈ្មោះ [redacted] បូរ៉ា ឈរឈ្មោះជាអ្នកទិញដីចំការស្វាយមានទំហំ១០៨០២ម៉ែត្រក្រឡា មានបង្កាន់ដៃ និងទីតាំងស្ថិតនៅដូចខាងលើ តាមពិតឈ្មោះ [redacted] ជៀប ពុំដែលមានដីនៅទីតាំងខាងលើនោះទេ ។ ដីខាងលើនេះឪពុកក្មេកកូនក្ដីខ្លួនឈ្មោះ [redacted] ហួត ទិញពីឈ្មោះ [redacted] អូនតាំងពីឆ្នាំ ១៩៨៩ ការទិញលក់ពុំមានធ្វើលិខិតស្នាមទេ ព្រោះជាទម្លាប់នៅសម័យនោះតែមានសាក្សីដឹងឮ ។ក្រោយពីទិញដីនោះរួចមកនៅឆ្នាំ១៩៩២ឈ្មោះ [redacted] ហួត និងឈ្មោះ [redacted] ហ្គិច បានធ្វើប្លង់កាន់កាប់ដីនោះ។ នៅឆ្នាំ២០២០ឈ្មោះ [redacted] បូរ៉ា លួចធ្វើលិខិតអំណោយផ្ដាច់ចុះថ្ងៃទី២៧ខែសីហាឆ្នាំ២០២០ឱ្យដីខាងលើទៅឱ្យឈ្មោះ [redacted] បូណា កូនក្ដីខ្លួនបានប្ដឹងតវ៉ាទៅមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីរាជធានីភ្នំពេញ,សង្កាត់ព្រែកថ្មី,ខណ្ឌច្បារអំពៅ ដើម្បីទប់ស្កាត់មិនឱ្យអាជ្ញាធរចេញប័ណ្ណកម្មសិទ្ធិឱ្យឈ្មោះហួត បូណា និងដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ។

-លួចក្លែងបន្លំធ្វើលិខិតលក់ដីក្លែងក្លាយចុះថ្ងៃទី០១ខែកញ្ញាឆ្នាំ១៩៩៥ដីទំហំ២៣៣ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ដោយឱ្យឈ្មោះ [redacted] ពើយ ឈរឈ្មោះជាអ្នកលក់ដី ឈ្មោះ [redacted] បូរ៉ាឈរឈ្មោះជាអ្នកទិញដី ។ ដីនេះពីមុនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ហាក់ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី២៦ខែមេសាឆ្នាំ១៩៩២ ក្រោយមកលក់ឱ្យឈ្មោះ [redacted] ហួត ។ឈ្មោះ [redacted] បូណា ដឹងច្បាស់ថាដីខាងលើនេះជារបស់ឪពុកម្ដាយបង្កើតខ្លួន បានចែកជាអំណោយឱ្យខ្លួននិងប្ដី ប៉ុន្តែឈ្មោះនេះលួចឃុបឃិតជាមួយបងប្រុស

ឈ្មោះហួតបូរ៉ា លួចក្លែងបន្លំធ្វើលិខិតអំណោយផ្តាច់ចុះថ្ងៃទី២៧ខែសីហាឆ្នាំ២០២០ បានក្លែងបន្លំធ្វើលិខិតបញ្ជាក់ប្រវត្តិដីចុះថ្ងៃទី០៣ខែកញ្ញាឆ្នាំ២០២០ដើម្បីទៅធ្វើប្លង់ដាក់ឈ្មោះហួតបូណា ម្នាក់ឯង មានបង្កាន់ដៃក្បាលដីលេខ១២១០០៧០៤០៧៦១ចុះថ្ងៃទី១៨ខែកុម្ភៈឆ្នាំ២០២០បច្ចុប្បន្នកំពុងដាក់ផ្លាកលក់ ។ ដីទំហំ៣៣៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ(បញ្ជាក់ក្នុងពាក្យបណ្តឹងមានទំហំ៤០៨ម៉ែត្រការ៉េ ជាក់ស្តែងទំហំ៣៣៥ម៉ែត្រការ៉េនោះទេ ។ ដីទំហំ២៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ជាទ្រព្យរួមបានមកពីឪពុកក្មេកចែកជាអំណោយចំណងដៃ ។ ដីទំហំ១៥៧២ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅជាទ្រព្យរួមបានមកពីឪពុកក្មេកចែកជាអំណោយចំណងដៃ កូនក្តីខ្លួននិងដើមចោទបានរស់នៅលើដីនិងផ្ទះនេះតាំងពីរៀបការមកដល់បច្ចុប្បន្ន គឺកូនក្តីខ្លួនមិនទាមទារទេប្រគល់ឲ្យទៅដើមចោទ ។

-ចំពោះបំណុលរួមជំពាក់បងប្អូនចំនួន២៤០,០០០ដុល្លារអាមេរិក(ម្ភៃបួនម៉ឺន)ក្នុងករណីដើមចោទមិនព្រមសង កូនក្តីខ្លួនសុខចិត្តទទួលបំណុលនេះតែម្នាក់ឯង ប៉ុន្តែឲ្យដើមចោទប្រគល់ដីទំហំ៣៣៥ម៉ែត្រការ៉េ(ទំហំ៤០៨ម៉ែត្រការ៉េ) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ចំនួនពាក់កណ្តាលឲ្យកូនក្តីខ្លួនក្នុងការទូទាត់បំណុលរួម ។ក្នុងចំណុច៣ នៃចំណុចទី១ ដើមចោទទាមទារសុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាមាន៖ ដីទំហំ៤០៨ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ។ ដីទំហំ៤០៨ម៉ែត្រការ៉េដែលដើមចោទអះអាងគឺមិនពិតទេ ដីមានទំហំពិតគឺ៥១៨ម៉ែត្រការ៉េ(បញ្ជាក់ចេញពីតារាងបិទប្រកាសក្បាលដីលេខ១១៧,១១៨ ដីក្នុងទំហំ៥១៨ម៉ែត្រការ៉េ ក្នុងនោះគឺមានដីទំហំ១៨៣ម៉ែត្រការ៉េជាដីកំពុងសាងសង់ផ្ទះ ជាដីប្អូនប្រុសកូនក្តីខ្លួនឈ្មោះ [redacted] សុខ ផ្ញើប្រាក់ពីប្រទេសស្វីសទិញ ដូច្នេះដីទំហំ១៨៣ម៉ែត្រការ៉េដែលមានក្នុងដីសរុបទំហំ៥១៨ម៉ែត្រការ៉េ មិនមែនជាទ្រព្យរួមទេ ដូចមានបិទតារាងប្រកាសក្បាលដីលេខ១១៨ទើបនៅក្នុងតារាងមិនបានដាក់ឈ្មោះបញ្ជាក់នរណាជាម្ចាស់កម្មសិទ្ធិ ។ ដូច្នេះទ្រព្យរួមដើមចោទអះអាង៤០៨ម៉ែត្រការ៉េ ជាក់ស្តែងមានតែ៣៣៥ម៉ែត្រការ៉េទេ។ ដីឡូត៍លេខ២៣២ មានទំហំបណ្តោយ១៧ម៉ែត្រទទឹង៨ម៉ែត្រ(១៣៦ម²) ស្ថិតនៅភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញមានកិច្ចសន្យាលក់ដីចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ មិនមែនជាទ្រព្យរួមទេ ដីនេះជាដីរបស់ម្ចាស់គេផ្សេង ។ សំណូមពរៈសុំឲ្យតុលាការបែងចែកស្មើគ្នានូវ

១.ដីចំការស្វាយទំហំ១០៨០២ម៉ែត្រក្រឡា មានបង្កាន់ដៃក្បាលដីលេខ១២១០០៧០៤០៧៦១ ស្ថិតនៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ។

២.ដីទំហំ៣៣៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ(ដើមចោទអះអាងក្នុងពាក្យបណ្តឹងចំនួន៤០៨ម៉ែត្រការ៉េ ជាក់ស្តែងមានទំហំ៣៣៥ម៉ែត្រការ៉េ ទេ ។

៣.សុំទទួលយកដីទំហំ២៥ម៉ែត្រការ៉េស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ជាទ្រព្យរួមដោយសុខចិត្តចេញប្រាក់ឲ្យដើមចោទចំនួន១០០០០ដុល្លារអាមេរិក(មួយម៉ឺន)។ បំណុលរួមចំនួន២៤០,០០០ដុល្លារអាមេរិក(ម្ភៃបួនម៉ឺន)សុំសងស្មើគ្នា ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានថ្លែងការណ៍តបថាៈខ្លួនឯកភាពលើសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនដែលថ្លែងខាងលើដដែល ។សូមបញ្ជាក់ថា កូនក្តីខ្លួននិងចុងចម្លើយមានអចលនទ្រព្យជាដីចំនួន០២ប្លង់ដូចមានដីទំហំ៤០៨ម៉ែត្រការ៉េ ស្ថិតនៅភូមុកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មិនមែនមានទំហំ៤០៨ម៉ែត្រការ៉េទេ ទំហំពិតប្រាកដគឺ៣៣៥ម៉ែត្រការ៉េ , ដីឡូត៍លេខ២៣២មានទំហំ

បណ្តោយ១៧ម៉ែត្រទទឹង៨ម៉ែត្រ(១៣៦ម$^{2}$ )ថាមិនមែនជាទ្រព្យរួមជារបស់ឈ្មោះ [redacted] សំបូរនោះមិនពិតទេ ។ ដីនេះមានឈ្មោះ [redacted] សំបូរ ជាម្ចាស់កម្មសិទ្ធិជាទ្រព្យប្អូនថ្លៃចុងចម្លើយ ប៉ុន្តែជាក់ស្តែងលុយទិញដីនេះគឺជាទ្រព្យសម្បត្តិរួមរបស់កូនក្តីខ្លួននិងចុងចម្លើយ កូនក្តីខ្លួននិងចុងចម្លើយពុំមានទ្រព្យរួមផ្សេងទៀតទេ។ ចំណែកដី០៣ប្លង់ទៀតគឺជាទ្រព្យដោយឡែករបស់កូនក្តីខ្លួនមាន:

-ដីចំការស្វាយទំហំ១០៨០២ម៉ែត្រក្រឡា មានបង្កាន់ដៃក្បាលដីលេខ១២១០០៧០៤ ០៧៦១ ស្ថិតនៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ។ដីនេះត្រូវបានអាជ្ញាធរចុះបញ្ជីដីធ្លីជាប្រពន្ធ័រួចហើយ បានមកពីការធ្វើអំណោយរបស់បងប្រុសឈ្មោះ [redacted] ប្ញវ៉ាំ មានលិខិតធ្វើអំណោយផ្តាច់លេខ៧១១/០២០ចុះថ្ងៃទី២៧ខែសីហាឆ្នាំ២០២០របស់ចៅសង្កាត់ព្រែកថ្មី ។

-ដីទំហំ២៥ម៉ែត្រការ៉េ(ដីនៅចំណុចច្រមុះជ្រូក) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ។ដីនេះត្រូវបានអាជ្ញាធរចុះបញ្ជីដីធ្លីជាប្រពន្ធ័រួចហើយមានក្បាលដីលេខ០៣០ បានមកពីការធ្វើអំណោយរបស់បងប្រុសឈ្មោះ [redacted] ប្ញវ៉ាំ មានលិខិតធ្វើអំណោយផ្តាច់លេខ៧១២/០២០ចុះថ្ងៃទី២៧ខែសីហាឆ្នាំ២០២០របស់ចៅសង្កាត់ព្រែកថ្មី និង ដីទំហំ១៦៣២ម៉ែត្រការ៉េ( ១៥៧២ថ្មី)ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ដីនេះត្រូវបានអាជ្ញាធរចុះបញ្ជីដីធ្លីជាប្រពន្ធ័រួចហើយមានក្បាលដីលេខ០២២ ជាទ្រព្យដោយឡែករបស់កូនក្តីខ្លួន បានមកពីការធ្វើអំណោយរបស់ម្តាយឈ្មោះ [redacted] ហ៊ុិច ដែលមានលិខិតធ្វើអំណោយផ្តាច់លេខ៦៦១/០២០ចុះថ្ងៃទី១៤ខែកក្កដាឆ្នាំ២០២០របស់ចៅសង្កាត់ព្រែកថ្មី។ យោងតាមលិខិតធ្វើអំណោយផ្តាច់ បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ដីចំនួន០៣កន្លែងខាងលើនេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់កូនក្តីខ្លួន ដែលបានមកពីអំណោយនៅអំឡុងពេលអាពាហ៍ពិពាហ៍ប៉ុណ្ណោះ គប្បីមិនចែកនោះទេ ស្របតាមមាត្រា៩៨០ កថាខណ្ឌទី២ ចំណុច “ក” នៃក្រមរដ្ឋប្បវេណី ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍បញ្ចប់ថា:កូនក្តីខ្លួននិងភាគីចុងចម្លើយ ពិតជារស់នៅមិនចុះសម្រុងគ្នា ឈ្លោះគ្នាញឹកញាប់និងបានរស់នៅបែកគ្នាជាយូរឆ្នាំមកហើយ ។ ចំពោះទ្រព្យសម្បត្តិរវាងកូនក្តីខ្លួននិងចុងចម្លើយ គឺមានតែដីចំនួន០២កន្លែងដែលកូនក្តីបានបញ្ជាក់ជូនប៉ុណ្ណោះ ចំណែកដី០៣កន្លែងផ្សេងទៀតគឺជាទ្រព្យដោយឡែករបស់កូនក្តីខ្លួនដែលទទួលបានជាអំណោយពីបងប្រុសឈ្មោះ [redacted] ប្ញវ៉ាំ និងម្តាយឈ្មោះ [redacted] ហ៊ុិច ដែលមានលិខិតធ្វើអំណោយផ្តាច់ត្រឹមត្រូវស្របតាមច្បាប់ ។ ចំណែកបំណុលរួម គឺកូនក្តីខ្លួនពុំមានទេ កូនក្តីខ្លួនពុំបានដឹងអំពីការខ្ចីប្រាក់រវាងភាគីចុងចម្លើយនិងម្ចាស់បំណុលឡើយ ។ សំណូមពរ:ការសុំលែងលះនិងសុំអំណាចមេបាលើកូនឯកភាពលើសេចក្តីថ្លែងការណ៍របស់កូនក្តី,សុំបែងចែកទ្រព្យសម្បត្តិរួមមានដីចំនួន០២កន្លែង៖

-ដីទំហំ៤០៨ម៉ែត្រការ៉េ (ទំហំជាក់ស្តែង៣៣៥ម$^{2}$)ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ និងលិខិតបញ្ជាក់ប្រវត្តិដីចុះថ្ងៃទី២១ ខែធ្នូឆ្នាំ២០១៨របស់ចៅសង្កាត់ព្រែកថ្មី និងដីឡូត៍លេខ២៣២មានទំហំបណ្តោយ១៧ម៉ែត្រទទឹង៨ម៉ែត្រ(១៣៦ម$^{2}$ )ស្ថិតនៅភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញមានកិច្ចសន្យាលក់ដីចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ ។



Scanned with CamScanner

-លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានថ្លែងការណ៍បញ្ចប់ថា: ខ្លួនឯកភាពលើសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួន និងសុំរក្សាសេចក្តីថ្លែងការណ៍ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ដដែល ។

**ង.ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**១/.ចំណុចវិវាទ៖**

**-តើការអះអាងរបស់ភាគីចុងចម្លើយថា ទ្រព្យសម្បត្តិមានដីចំការស្វាយទំហំ១០៩០២ម៉ែត្រការ៉េស្ថិតនៅភូមិ** ចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ,ដីទំហំ២៥ម៉ែត្រការ៉េ និងដីទំហំ(១៦៣២)១៥៧២ថ្មីម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ជាទ្រព្យសម្បត្តិរួម តើត្រឹមត្រូវដែរឬទេ ? ។

**២/. ចំណុចគ្មានវិវាទ៖**

-គូភាគីឯកភាពលែងលះ,ឯកភាពប្រគល់អំណាចមេបាលើកូន០១នាក់ទៅឱ្យភាគីដើមចោទ។

## II.ការពិនិត្យភស្តុតាង

**១ ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.ពាក្យសុំជូនភស្តុតាងចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០២១របស់លោក [redacted] មេធាវីដើមចោទ និងឯកសារភ្ជាប់មកជាមួយមានក្នុងសំណុំរឿង ។

**២ ភស្តុតាងជាឯកសាររបស់ចុងចម្លើយ ៖**

១.១.ពាក្យសុំជូនភស្តុតាងចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០២១របស់មេធាវី [redacted] មេធាវីចុងចម្លើយ និងឯកសារភ្ជាប់មកជាមួយមានក្នុងសំណុំរឿង ។

## សំអាងហេតុ

១- តាមលទ្ធផលនៃការសាកសួរ និងពិនិត្យភស្តុតាង នៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖ ដើមចោទឈ្មោះ [redacted] បូណា និងចុងចម្លើយឈ្មោះ [redacted] សុវិចិត្រ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ គូភាគីរួមរស់ជាមួយគ្នាមិនចុះសំរុងធ្វើឱ្យដើមចោទ អស់មនោសញ្ចេតនាពីចុងចម្លើយ ហើយចុងចម្លើយក៏ឯកភាពលែងលះពីដើមចោទដែរ គូភាគីបានបែកលំនៅពីគ្នាតាំងពី ២០១៥ រហូតដល់សព្វថ្ងៃ ។ គូភាគីបង្កើតបានកូន០១នាក់ឈ្មោះ [redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ ខែកក្កដាឆ្នាំ២០០៤ ។ គូភាគីបង្កើតបានទ្រព្យសម្បត្តិជាអចលនវត្ថុមួយចំនួនដូចខាងក្រោម ៖

-ដីផ្ទះលេខ១៤ផ្លូវលេខ៣៦៩មានទំហំ៤០៨ម²(ទំហំជាក់ស្តែង៣៣៥ម²)ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤របស់ឈ្មោះ [redacted] ទេពី ផ្ទេរទៅឱ្យឈ្មោះ [redacted] អាន និងប្រពន្ធឈ្មោះ [redacted] ស្រ៊ីវ ហើយឈ្មោះ [redacted] អាន និងឈ្មោះ [redacted] ស្រ៊ីវ លក់បន្តទៅឱ្យឈ្មោះ [redacted] សុវិចិត្រ និងឈ្មោះ [redacted] បូណា និងតាមលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ មានស្នាមមេដៃឈ្មោះ [redacted] មេភូមិកោះក្របី និងចុះហត្ថលេខាដោយលោក [redacted] ចៅសង្កាត់ព្រែកថ្មី ។

២-គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ០១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ ។

៣-តុលាការបានធ្វើការផ្សះផ្សាគូភាគីគ្រប់ដំណាក់កាលនៃនីតិវិធី តែគូភាគីពុំព្រមសះជានិងគ្នាវិញឡើយ។ ហើយគូភាគីបានឯកភាពលែងលះដោយស្មគ្រ័ចិត្តពុំមានបង្ខិតបង្ខំឡើយ ។ ដូចនេះគប្បីតុលាការសម្រេចតាមឆន្ទៈរបស់គូភាគី ។

៤-គូភាគីមានកូន០១នាក់ឈ្មោះ [redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ ។ ភាគីដើមចោទបានសុំអំណាចមេបាលើកូន០១នាក់នេះ ហើយភាគីចុងចំលើយក៏ឯកភាពប្រគល់អំណាចមេបាលើកូនម្នាក់នេះផងដែរ។ ដូច្នេះគប្បីតុលាការសម្រេចតាមឆន្ទៈរបស់គូភាគី ។

៥-ភាគីដើមចោទសុំសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនតាមលទ្ធភាព ចំណែកភាគីចុងចម្លើយឯកភាពផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនតាមលទ្ធភាពផងដែរ ។ ដូច្នេះតុលាការគប្បីសម្រេចឱ្យភាគីចុងចម្លើយផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនតាមលទ្ធភាពរហូតដល់កូនមានវ័យនីតិភាព។

៦-តាមលិខិតបញ្ជាក់ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ របស់លោកប៉េ ប៉ាក់មេភូមិកោះក្របីថាៈដីមួយកន្លែងមានក្នុងតារាងក្បាលដីក្នុងលេខ១១៧ទំហំ៤០៨ម៉ែត្រការ៉េ(ជាក់ស្តែងទំហំ៣៣៥ម៉ែត្រការ៉េ)ស្ថិតនៅភូមិកោះក្របីសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងដីទំហំ១៦៣២ម$^2$(ទំហំថ្មី១៥៧២ម៉ែត្រការ៉េ គឺជាដីរបស់ឪពុកម្តាយក្មេកឈ្មោះ [redacted] ហួត បានប្រគល់ឱ្យឈ្មោះ [redacted] បូណា និងឈ្មោះ [redacted] សុវិចិត្រ កាន់កាប់និងប្រើប្រាស់តាំងពីចុងឆ្នាំ២០០៦រហូតមកដល់បច្ចុប្បន្ន ហើយការប្រគល់នេះពុំមានលាយល័ក្ខអក្សរគ្រាន់តែបញ្ជាក់ប្រាប់មិត្តភក្តិនិងសាច់ញាតិបានដឹងឮ ។ ផ្អែកលើលិខិតបដិសេធចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់លោកប៉េ ប៉ាក់មេភូមិកោះក្របីដែលថាៈខ្លួនសុំបដិសេធសេចក្តីបញ្ជាក់របស់ខ្លួនដែលស្ថិតនៅតុលាការទាំងអស់ចាប់ពីថ្ងៃនេះតទៅ ដោយខ្លួនគិតថា ការបញ្ជាក់នេះសម្រាប់ប្រើប្រាស់ក្នុងការបង្ហាញដៃគូអាជីវកម្មរបស់គាត់តែប៉ុណ្ណោះ។ ហើយតារាងលេខ១១៧ មានឈ្មោះ [redacted] សុវិចិត្រ(ប្តី)ឈ្មោះ [redacted] បូណា(ប្រពន្ធ) បញ្ជាក់ថាៈ(ទ្រព្យខាងប្រពន្ធ) ដូចមានលិខិតបញ្ជាក់ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១របស់ឈ្មោះ [redacted] ហ៊ួច(ម្តាយបង្កើតឈ្មោះ [redacted] បូណា) ថា ខ្លួននិងស្វាមីឈ្មោះ [redacted] ហួត ខ្លួនទាំងពីរនាក់បានបែងចែកទ្រព្យសម្បត្តិជាអចលនវត្ថុដល់កូនបង្កើតឈ្មោះ [redacted] បូរ៉ា និងឈ្មោះ [redacted] បូណា រួចរាល់ហើយ ។ ហើយទ្រព្យទាំងអស់ដែលបានផ្ទេរកម្មសិទ្ធិនោះគឺជាទ្រព្យសម្បត្តិរបស់ពួកខ្លួនប្រគល់ឱ្យកូនបង្កើតទាំងពីរខាងលើ ដោយពុំមានជាប់ពាក់ព័ន្ធជាមួយកូនប្រសារឈ្មោះ [redacted] សុវិចិត្រ ឬចែកជាអំណោយចំណងដៃអាពាហ៍ពិពាហ៍ដល់កូនប្រសារឈ្មោះ [redacted] សុវិចិត្រ នោះទេ ។

៧-តាមសេចក្តីថ្លែងការណ៍បញ្ចប់របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទថាៈសុំរក្សាសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ខែធ្នូឆ្នាំ២០២៣ និងសេចក្តីថ្លែងការណ៍ដែលបានផ្តល់ជូនតុលាការ ។

៨-តាមសេចក្តីថ្លែងការណ៍បញ្ចប់របស់លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថាៈសុំរក្សាសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ខែធ្នូឆ្នាំ២០២៣ និងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣ ដែលបានផ្តល់ជូនតុលាការ ។

៩-ភាគីដើមចោទបានអះអាងថា ដីផ្ទះលេខ១៤ផ្លូវលេខ៣៦៩មានទំហំ៤០៨ម$^2$ (ជាក់ស្តែងទំហំ៣៣៥ម$^2$)ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤របស់ឈ្មោះ [redacted] ទេពី ផ្ទេរទៅឱ្យឈ្មោះ [redacted] អាន និងប្រពន្ធឈ្មោះ [redacted] ស្រ៊ីវ ហើយឈ្មោះ [redacted] អាន និងឈ្មោះ [redacted] ស្រ៊ីវ លក់បន្តទៅឱ្យឈ្មោះ [redacted] សុវិចិត្រ និងឈ្មោះហួត បូណា និងតាមលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨មានស្នាមមេដៃឈ្មោះ [redacted] ប៉ាក់ មេភូមិកោះក្របី និងចុះហត្ថលេខាដោយលោក [redacted] ចៅសង្កាត់ព្រែកថ្មី ។ ដូច្នេះតាមអង្គហេតុខាងលើបានបង្ហាញថា ដីផ្ទះលេខ១៤ផ្លូវលេខ៣៦៩មានទំហំ៤០៨ម$^2$(ជាក់ស្តែងទំហំ៣៣៥ម$^2$) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ



Scanned with CamScanner

គឺជាទ្រព្យសម្បត្តិរួមរបស់គូភាគី ។ ភាគីដើមចោទសុំលក់យកប្រាក់បែងចែកជាពីរចំណែកស្មើគ្នា ។ ដូច្នេះគប្បីតុលាការសម្រេចតាមសំណូមពររបស់ភាគីដើមចោទ ។

៥-ភាគីដើមចោទបានអះអាងថាដីឡូត៍លេខ២៣២ មានទំហំបណ្ដោយ១៧ម៉ែត្រទទឹង៨ម៉ែត្រ(១៣៦ម² ) ស្ថិតនៅភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានកិច្ចសន្យាលក់ដីចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ អ្នកលក់ឈ្មោះ[redacted]សុខហេង និងអ្នកទិញឈ្មោះ[redacted] សំបូរ មិនមានឈ្មោះគូភាគីក្នុងកិច្ចសន្យាលក់ដីចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ ឡើយ ។ ដូច្នេះដីឡូត៍លេខ២៣២ មិនមែនជាទ្រព្យសម្បត្តិរួមរបស់គូភាគីទេ ។

៦-ភាគីចុងចម្លើយបានអះអាងថាៈដីចំការស្វាយទំហំ១០៩០២ម៉ែត្រការ៉េស្ថិតនៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ,ដីទំហំ២៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ និងដីទំហំ១៦៣២(ទំហំថ្មី១៥៧២ម៉ែត្រការ៉េ) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ គឺជាទ្រព្យសម្បត្តិរួម ។ ចំណែកភាគីដើមចោទអះអាងថាៈដី០៣កន្លែងខាងលើដែលចុងចម្លើយអះអាងថាជាទ្រព្យសម្បត្តិរួមនោះ គឺពុំពិតដូចការអះអាងទេ គឺជាទ្រព្យរបស់បងប្រុសខ្លួនឈ្មោះ[redacted] បូរ៉ា និងម្ដាយបង្កើតឈ្មោះហេង ហ្គេច បានផ្ទេរមកឱ្យខ្លួនតាមលិខិតធ្វើអំណោយផ្ដាច់ចុះថ្ងៃទី២៧ ខែសីហាឆ្នាំ២០២០ ដោយមានលោក[redacted] ប្រធានភូមិចំពុះក្អែក១ លោក [redacted]មេភូមិកោះក្របី និងហត្ថលេខារបស់លោក[redacted] ចៅសង្កាត់ព្រែកថ្មី ដឹងឮផងដែរ ហើយដីខាងលើបានចុះបញ្ជីជាប្រព័ន្ធរួចរាល់ហើយ(ប្លង់រឹងអិលម៉ាប)។តាមលិខិតបញ្ជាក់របស់ឈ្មោះ[redacted] សុខុមឈ្មោះ[redacted] ផេងឈ្មោះ[redacted] ចន្ថា ឈ្មោះ [redacted] អូន ឈ្មោះហោធីម ឈ្មោះ [redacted]ឈាន និងឈ្មោះ តូចហ៊ុន(អតីតមេភូមិចំពុះក្អែក១) បញ្ជាក់លើដីដែលមានទំហំ១០៩០២ម៉ែត្រការ៉េ ស្ថិតនៅភូមិចំពុះក្អែក១ថា ជាដីរបស់ឈ្មោះ[redacted] សុវិចិត្រ និងឈ្មោះ[redacted]បូណា បានកាន់កាប់បន្តពីឪពុកក្មេកឈ្មោះ[redacted] ហួត ចែកជាអំណោយមុនស្លាប់ជាចំណែងដៃកូនទាំងពីរ ។ ភាគីចុងចម្លើយផ្ដល់ភស្តុតាងពុំបានច្បាស់លាស់ធ្វើឱ្យតុលាការពុំអាចកំណត់ថាដីនេះជាកម្មសិទ្ធិរបស់គូភាគីឡើយ។ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ភាគីចុងចម្លើយដែលសុំបែងចែកទ្រព្យសម្បត្តិដីចំការស្វាយទំហំ១០៩០២ម៉ែត្រការ៉េស្ថិតនៅភូមិចំពុះក្អែក១ ដីទំហំ២៥ម៉ែត្រការ៉េ និងដីទំហំ១៦៣២(ទំហំថ្មី១៥៧២ម៉ែត្រការ៉េ) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

៦-ភាគីចុងចម្លើយបានអះអាងថាបំណុលដែលខ្លួនជំពាក់បងប្អូនសរុបចំនួន២៤០.០០០ម៉ឺនដុល្លារអាមេរិក (ម្ភៃបួនម៉ឺន) ។ តាមការពិនិត្យភស្តុតាងឃើញថា លិខិតប្រគល់និងលិខិតខ្ចីប្រាក់ដែលភាគីចុងចម្លើយបានផ្ដល់ភស្តុតាងជូនតុលាការ អ្នកខ្ចីគឺមានតែឈ្មោះ[redacted] សុវិចិត្រ ពុំមានឈ្មោះ[redacted] បូណា ចូលរួមខ្ចីប្រាក់នោះទេ ។ ដូច្នេះ គប្បីតុលាការមិនពិចារណាពីបំណុលរបស់គូភាគីឡើយ ។

៨- ប្រាក់ប្រដាប់ក្ដី គប្បីដាក់បន្ទុកលើគូភាគី ។

## សេចក្ដីសម្រេចបញ្ចប់

១. ឲ្យដើមចោទឈ្មោះ[redacted]បូណា និងចុងចម្លើយឈ្មោះ[redacted] សុវិចិត្រ លែងលះពីគ្នា តាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី ។

២.កំណត់យកភាគីដើមចោទឈ្មោះ[redacted] បូណា ជាអ្នកមានអំណាចមេបាលើកូន០១នាក់ឈ្មោះ[redacted] វិចិត្រ សត្យា ភេទប្រុស កើតថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ ។



Scanned with CamScanner

ភាគីដែលពុំមានអំណាចមេបាលើកូន មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូននេះបាន ។ ភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា១០៣៧ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៣.អោយភាគីចុងចម្លើយផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនឈ្មោះ [redacted] វិចិត្រសត្យា ភេទប្រុស កើតថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ តាមលទ្ធភាពរហូត ដល់កូនមានវ័យនីតិភាព ។

៤.ទ្រព្យសម្បត្តិរួមមានដីផ្ទះលេខ១៤ ផ្លូវលេខ៣៦៩ មានទំហំ៤០៨ម៉ែត្រការ៉េ(ទំហំជាក់ស្តែង៣៣៥ម៉ែត្រការ៉េ)ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរកម្មសិទ្ធិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅសង្កាត់ព្រែកថ្មី លក់យកប្រាក់ចែកជាពីរចំណែកស្មើគ្នា។

៥.ច្រានចោលការទាមទាររបស់ភាគីដើមចោទដែលសុំបែងចែកទ្រព្យសម្បត្តិមានដីឡូត៍លេខ២៣២ ទំហំបណ្តោយ១៧ម៉ែត្រទទឹង៨ម៉ែត្រ(១៣៦ម²)ស្ថិតនៅភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

៦.ច្រានចោលការទាមទាររបស់ភាគីចុងចម្លើយដែលសុំបែងចែកទ្រព្យសម្បត្តិមានដីចំការស្វាយទំហំ១០៩០២ម៉ែត្រការ៉េស្ថិតនៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ,ដីទំហំ២៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ និងដីទំហំ១៦៣២(ទំហំថ្មី១៥៧២ម៉ែត្រការ៉េ) ស្ថិតនៅភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី។

៧.សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទីនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខគូភាគី និងមេធាវីតំណាងដោយអាណត្តិ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០១ខែ(មួយ)ខែគិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១រោច ខែមគសិរ ឆ្នាំឆ្លូវ ត្រីស័ក ពស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មករាឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]